

# របាយការណ៍ប្រចាំឆ្នាំ ២០២៥
# របស់មន្ទីរពេទ្យកុមារអង្គរ

# Angkor Hospital for Children
# 2025 Annual Report

ahc

# មាតិកា | Table of contents


ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃរបស់មន្ទីរពេទ្យកុមារអង្គរ 2
សាររបស់សាស្ត្រាចារ្យវេជ្ជបណ្ឌិត ងួន ច័ន្ទភក្ត្រា នាយកមន្ទីរពេទ្យកុមារអង្គរ 4
ទិន្នន័យឆ្នាំ២០២៥ 6
សូចនាកររាស់វែងសកម្មភាពអនុវត្តការងារឆ្នាំ២០២៥ 9
ការអភិវឌ្ឍថ្មីៗក្នុងឆ្នាំ២០២៥ 11
ការបោះជំហានឆ្ពោះទៅមុខរបស់មន្ទីរពេទ្យកុមារអង្គរ 17
ការលើកកម្ពស់សម្រាប់អនាគតជំនាន់ក្រោយ 22
- អបអរសាទរដល់អ្នកផ្តល់ប្រឹក្សាផ្នែកវេជ្ជសាស្រ្ត ក្នុងឆ្នាំ២០២៥ 24
- ជួបជាមួយវេជ្ជបណ្ឌិតបញ្ចប់ការសិក្សារបស់យើង 26

ព្រឹត្តិការណ៍អែអង្គាសថវិកាធំៗរបស់មន្ទីរពេទ្យកុមារអង្គរ 31
អភិបាលកិច្ច 35
របាយការណ៍ហិរញ្ញវត្ថុ 37
សេចក្តីថ្លែងអំណរគុណ 39
Our vision, mission, & values 43
Message from our CEO 45
2025 by the numbers 47
2025 key performance indicators 50
Clinical excellence & innovation 52
AHC beyond our hospital's walls 58
Empowering the next generation 63
- Celebrating our mentors 65
- Meet our graduates 67

AHC events 72
Governance 76
Finances 78
Thank you 80




**ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ**

សាររបស់សាស្ត្រាចារ្យវេជ្ជបណ្ឌិត ងួន ច័ន្ទភក្រ្តា

ទិន្នន័យឆ្នាំ២០២៥

សូចនាកររាស់វែងសកម្មភាពអនុវត្តការងារឆ្នាំ២០២៥

ការអភិវឌ្ឍថ្មីៗក្នុងឆ្នាំ២០២៥

ការបោះជំហានឆ្ពោះទៅមុខរបស់មន្ទីរពេទ្យកុមារអង្គរ

ការលើកកម្ពស់សម្រាប់អនាគតជំនាន់ក្រោយ

អបអរសាទរដល់អ្នកផ្តល់ប្រឹក្សាក្នុងឆ្នាំ២០២៥

ជួបជាមួយវេជ្ជបណ្ឌិតបញ្ចប់ការសិក្សារបស់យើង

ព្រឹត្តិការណ៍ធំៗរបស់មន្ទីរពេទ្យកុមារអង្គរ

អភិបាលកិច្ច

របាយការណ៍ហិរញ្ញវត្ថុ

សេចក្តីថ្លែងអំណរគុណ






## ចក្ខុវិស័យរបស់យើង

**កុមារកម្ពុជាគ្រប់រូបក្នុងប្រទេសកម្ពុជា ទទួលបាននូវការថែទាំសុខភាពប្រកបដោយគុណភាពខ្ពស់ និងសេចក្តីមេត្តាករុណា មិនថាពួកគេរស់នៅទីណា មានឬមិនមានលទ្ធភាពចូលរួមភាគទានក៏ដោយ**

## បេសកកម្មរបស់យើង

**ធ្វើឱ្យប្រសើរឡើងនូវសេវាថែទាំសុខភាពសម្រាប់កុមារគ្រប់រូបនៅក្នុងប្រទេសកម្ពុជា**

## គុណតម្លៃរបស់យើង

### មេត្តាធម៌:

យើងស្តាប់ដោយយកចិត្តទុកដាក់ បង្ហាញពីការគោរព និងផ្តល់តម្លៃការថែទាំព្យាបាល ដូចដែលអ្វីដែលយើងចង់បានសម្រាប់គ្រួសារ និងខ្លួនរបស់យើងផ្ទាល់

### គុណភាពនៃការថែទាំ:

យើងផ្តល់ការថែទាំសុខភាពប្រកបដោយគុណភាពខ្ពស់ និងប្តេជ្ញាកែលម្អជាប់ជាបន្ត។ គុណភាពនៃការថែទាំរបស់យើងឆ្លុះបញ្ចាំងលើគ្រប់សកម្មភាពរួមមាន:

- **សុវត្ថិភាព:** ធានាថាអ្នកជំងឺ និងបុគ្គលិកមិនទទួលរងគ្រោះថ្នាក់ និងផលប៉ះពាល់ពីការថែទាំព្យាបាល
- **ប្រសិទ្ធផល:** ផ្តល់ការព្យាបាលតាមគោលការណ៍ណែនាំផ្អែកតាមភស្តុតាងវិទ្យាសាស្ត្របច្ចុប្បន្ន
- **ផ្តោតលើអ្នកជំងឺ:** ធានាសេវាថែទាំរបស់យើងឆ្លើយតប គោរពនូវតម្លៃនិងជម្រើសរបស់អ្នកជំងឺ
- **លទ្ធភាពទទួលសេវា:** ផ្តល់សេវាទាន់ពេលវេលា អាចទទួលយកបានសម្រាប់អ្នកជំងឺ និងអនុលោមតាមបទដ្ឋានសុខាភិបាល
- **ប្រសិទ្ធភាព:** ចៀសវាងការចំណាយមិនចាំបាច់ និងប្រើប្រាស់ធនធានសមស្របដើម្បីទទួលបានអត្ថប្រយោជន៍ល្អបំផុត
- **សមធម៌:** ផ្តល់សេវាថែទាំសុខភាពដល់កុមារគ្រប់រូបដោយមិនរើសអើង

### ជំនាញ:

យើងមានមោទនភាព ចំពោះការរក្សានូវជំនាញ តាមរយៈការរៀនសូត្រជាប្រចាំ និងចែករំលែកចំណេះដឹង និងជំនាញ

### សុចរិតភាព:

យើងស្មោះត្រង់ បើកចំហ និងទទួលខុសត្រូវចំពោះរាល់សកម្មភាពរបស់យើង។ សុចរិតភាពជាមូលដ្ឋានគ្រឹះសម្រាប់គ្រប់កិច្ចការងាររបស់យើង

ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ

**សាររបស់សាស្ត្រាចារ្យវេជ្ជបណ្ឌិត ងួន ច័ន្ទភក្ត្រា**

ទិន្នន័យឆ្នាំ២០២៥

សូចនាកររាស់វែងសកម្មភាពអនុវត្តការងារឆ្នាំ២០២៥

ការអភិវឌ្ឍថ្មីៗក្នុងឆ្នាំ២០២៥

ការបោះជំហានឆ្ពោះទៅមុខរបស់មន្ទីរពេទ្យកុមារអង្គរ

ការលើកកម្ពស់សម្រាប់អនាគតជំនាន់ក្រោយ

អបអរសាទរដល់អ្នកផ្តល់ប្រឹក្សាក្នុងឆ្នាំ២០២៥

ជួបជាមួយវេជ្ជបណ្ឌិតបញ្ចប់ការសិក្សារបស់យើង

ព្រឹត្តិការណ៍ធំៗរបស់មន្ទីរពេទ្យកុមារអង្គរ

អភិបាលកិច្ច

របាយការណ៍ហិរញ្ញវត្ថុ

សេចក្តីថ្លែងអំណរគុណ





## សាររបស់

# សាស្ត្រាចារ្យវេជ្ជបណ្ឌិត ងួន ច័ន្ទភក្ត្រា

## នាយកមន្ទីរពេទ្យកុមារអង្គរ

ជូនចំពោះមិត្តអ្នកគាំទ្រមន្ទីរពេទ្យកុមារអង្គរទាំងអស់ជាទីរាប់អាន

ឆ្នាំនេះ បានសបញ្ជាក់ឲ្យយើងឃើញថាតម្រូវការនៃការគាំពារសុខភាពរបស់កុមារមានការកើនឡើងខ្ពស់លើសពីអ្វីដែលមន្ទីរពេទ្យរបស់យើងរំពឹងទុក។ ភាពតានតឹងនៅតាមព្រំដែនបានប៉ះពាល់យ៉ាងច្រើនដល់ប្រជាជននៅតាមសហគមន៍។ ក្រុមការងាររបស់យើងនៅតែប្ដេជ្ញាចិត្តក្នុងការផ្តល់ការគាំទ្រដល់កុមារ និងគ្រួសារដែលងាយរងគ្រោះទាំងនៅក្នុងមន្ទីរពេទ្យផ្ទាល់ និងនៅក្នុងសហគមន៍។ នៅក្នុងគ្រាលំបាកនេះ ការថែទាំសុខភាពកាន់តែមានសារៈសំខាន់ ហើយយើងពិតជាមានមោទនភាពដែលបានក្លាយជាអង្គភាពមួយដើម្បីជួយសម្រួលបន្ទុករបស់ប្រជាជនកម្ពុជា។

ក្នុងពេលជាមួយគ្នានេះដែរ យើងក៏បានបន្តពង្រឹងបន្ថែមនូវឯកទេសថែទាំកុមារមួយចំនួនចាប់ពីការព្យាបាល និងថែទាំរបួសប៉ះទង្គិចធ្ងន់ធ្ងរ រហូតដល់សេវាកម្មទំនើបៗ ដូចជាការឆ្លុះទងសួតដោយម៉ាស៊ីនទំនើប bronchoscopy និងការបណ្តុះបណ្តាលជាបន្តបន្ទាប់ជាមួយអ្នកជំនាញសុខភាពមកពីអន្តរជាតិដែលបានជួយជម្រុញក្រុមគ្រូពេទ្យរបស់យើងអាចបន្តជួយសង្គ្រោះដល់កុមារជាច្រើនឱ្យរស់រានមានជីវិត និងលូតលាស់មានសុខភាពល្អសម្រាប់អនាគតកម្ពុជា។

យើងក៏នូវតែបន្តលើកស្ទួយដល់អ្នកជំនាញសុខភាពកុមារនៅកម្ពុជាបន្ថែមទៀត តាមរយៈការជួយពង្រឹងសមត្ថភាពឲ្យរឹងមាំ និងប្រកបដោយចីរភាពសម្រាប់ការថែទាំសុខភាពកុមារទូទាំងប្រទេស។

ដូចគ្នានេះដែរ ឆ្នាំនេះការចូលរួមរបស់ប្រជាពលរដ្ឋកម្ពុជាយើងបានបង្ហាញពីកម្លាំងសាមគ្គីដ៏រឹងមាំផងដែរ។ ការបរិច្ចាគនៅក្នុងប្រទេសបានក្លាយជាកម្លាំងជម្រុញទឹកចិត្តក្នុងការបន្តពង្រឹង និងប្តេជ្ញាចិត្តរួមគ្នាក្នុងការលើកស្ទួយប្រព័ន្ធថែទាំសុខភាពកុមារនៅកម្ពុជា។ ក្នុងពេលអនាគត យើងនៅតែប្តេជ្ញាចិត្តក្នុងការពង្រីកជំនាញឯកទេសថែទាំកុមារដើម្បីធានាថាកុមារកាន់តែច្រើនអាចទទួលបានការព្យាបាលដែលពួកគេត្រូវការ។

សូមអរគុណយ៉ាងជ្រាលជ្រៅលើការចូលរួមចំណែកនៅក្នុងបេសសកម្មដ៏ធំធេងមួយនេះ និងជួយបង្កើតអនាគតដ៏ភ្លឺស្វាងសម្រាប់កុមារនៅក្នុងប្រទេសកម្ពុជាទាំងអស់។

ដោយសេចក្តីគោរពស្រឡាញ់

សាស្ត្រាចារ្យវេជ្ជបណ្ឌិត ងួន ច័ន្ទភក្ត្រា
នាយកមន្ទីរពេទ្យកុមារអង្គរ (AHC)

ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ

សាររបស់សាស្ត្រាចារ្យវេជ្ជបណ្ឌិត ដួន ច័ន្ទភក្ត្រា

**ទិន្នន័យឆ្នាំ២០២៥**

សូចនាករវាស់វែងសកម្មភាពអនុវត្តការងារឆ្នាំ២០២៥

ការអភិវឌ្ឍថ្មីៗក្នុងឆ្នាំ២០២៥

ការបោះជំហានឆ្ពោះទៅមុខរបស់មន្ទីរពេទ្យកុមារអង្គរ

ការលើកកម្ពស់សម្រាប់អនាគតជំនាន់ក្រោយ

អបអរសាទរដល់អ្នកផ្តល់ប្រឹក្សាក្នុងឆ្នាំ២០២៥

ជួបជាមួយវេជ្ជបណ្ឌិតបញ្ចប់ការសិក្សារបស់យើង

ព្រឹត្តិការណ៍ធំៗរបស់មន្ទីរពេទ្យកុមារអង្គរ

អភិបាលកិច្ច

របាយការណ៍ហិរញ្ញវត្ថុ

សេចក្តីថ្លែងអំណរគុណ




## ទិន្នន័យឆ្នាំ២០២៥

# ១១៥ ១២៧

ចំនួនករណីកុមារដែលបានពិនិត្យ និងព្យាបាលនៅផ្នែកពិគ្រោះជំងឺក្រៅ






## ៤ ៨៥៨

ចំនួនករណីកុមារដែលបានសម្រាកពិនិត្យ និងព្យាបាលនៅផ្នែកជំងឺសម្រាកពេទ្យ និងផ្នែកវះកាត់



## ២៥ ០៤៧

ចំនួនករណីវះកាត់និងការពិគ្រោះជំងឺលើកុមាររួមបញ្ចូលការវះកាត់តូច និងវះកាត់ធំ នៅក្នុងផ្នែកវះកាត់



## ៤១៥

ចំនួនទារកមិនគ្រប់ខែនិងទើបកើតបានទទួលការព្យាបាល និងថែទាំនៅផ្នែកថែទាំទារក



## ១ ៦៦៨

ចំនួនករណីកុមារបានទទួលការព្យាបាលនៅផ្នែកជំងឺធ្ងន់កុមារ

# ២២៧ ០៦៣

ចំនួនវគ្គមានអ្នកចូលរួមវគ្គអប់រំសុខភាពនៅតាមសហគមន៍ ដើម្បីបង្កើនចំណេះដឹងក្នុងការបង្ការជំងឺដង្កាត់ផ្សេងៗនៅក្នុងភូមិ សាលារៀន ក្នុងសហគមន៍ និងនៅក្នុងមន្ទីរពេទ្យ





## ៧៨ ២៨៥

ចំនួនវគ្គមានអ្នកចូលរួមវគ្គអប់រំបណ្តុះបណ្តាលតាមរយៈអនឡាញ និងដោយផ្ទាល់នៅក្នុងមន្ទីរពេទ្យកុមារអង្គរ ដោយរាប់បញ្ចូលមន្ត្រីសុខាភិបាល គិលានុបដ្ឋាក និស្សិតពេទ្យ និងបុគ្គលិកមន្ទីរពេទ្យកុមារអង្គរ



## ១១

ចំនួនស្ថាប័នសុខភាពបានទទួលការគាំទ្រដើម្បីលើកម្ពស់ ការថែទាំអ្នកជំងឺ បានទទួលការបំពាក់សម្ភារៈបរិក្ខារពេទ្យ ការបណ្តុះបណ្តាល និងការណែនាំ



## ៦១៩

ចំនួនវគ្គមានបុគ្គលិកមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលបង្វឹកនៅទីងកន្លែង (mentorship)



## ៨

វេជ្ជបណ្ឌិតចំនួនពីររូបបានបញ្ចប់ការបណ្តុះបណ្តាលឯកទេស និងវេជ្ជបណ្ឌិតចំនួនប្រាំមួយរូបបានបញ្ចប់ការសិក្សារយៈពេលមួយឆ្នាំសម្រាប់វគ្គបណ្តុះបណ្តោលជំងឺកុមារទូទៅ



## ៦៣

បុគ្គលិកមណ្ឌលសុខភាព និងមន្ទីរពេទ្យដែលបានទទួលការបណ្តុះបណ្តាលជំនាញថែទាំទារកទើបនឹងកើត

ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ

សាររបស់សាស្ត្រាចារ្យវេជ្ជបណ្ឌិត ដួន ច័ន្ទភក្ត្រា

ទិន្នន័យឆ្នាំ២០២៥

**សូចនាកររាស់វែងសកម្មភាពអនុវត្តការងារឆ្នាំ២០២៥**

ការអភិវឌ្ឍថ្មីៗក្នុងឆ្នាំ២០២៥

ការបោះជំហានឆ្ពោះទៅមុខរបស់មន្ទីរពេទ្យកុមារអង្គរ

ការលើកកម្ពស់សម្រាប់អនាគតជំនាន់ក្រោយ

អបអរសាទរដល់អ្នកផ្តល់ប្រឹក្សាក្នុងឆ្នាំ២០២៥

ជួបជាមួយវេជ្ជបណ្ឌិតបញ្ចប់ការសិក្សារបស់យើង

ព្រឹត្តិការណ៍ធំៗរបស់មន្ទីរពេទ្យកុមារអង្គរ

អភិបាលកិច្ច

របាយការណ៍ហិរញ្ញវត្ថុ

សេចក្តីថ្លែងអំណរគុណ



# សូចនាកររវាស់វែងសកម្មភាពអនុវត្តការងារឆ្នាំ២០២៥






ទិន្នន័យលទ្ធផលការងារពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០២៥ បានបង្ហាញឱ្យឃើញពីការប្តេជ្ញាចិត្តឥតឈប់ឈររបស់មន្ទីរពេទ្យកុមារអង្គរ ក្នុងការបង្កើតបរិយាកាសសុវត្ថិភាព សុខុមាលភាព និងប្រសិទ្ធភាពសម្រាប់កុមារគ្រប់រូប ដែលមកទទួលសេវាព្យាបាលនៅទីនេះ។

សមិទ្ធផលដ៏ធំធេងមួយក្នុងផ្នែកសុវត្ថិភាពកុមារ គឺការកាត់បន្ថយជាលំដាប់នៃអត្រាឆ្លងមេរោគនៅក្នុងមន្ទីរពេទ្យ ដែលបានធ្លាក់ចុះពី **៣,៩%** មកនៅកម្រិតទាបបំផុតមិនធ្លាប់មានគឺ **២,៤២%** ក្នុងឆ្នាំ ២០២៥។ នេះបង្ហាញថាកុមារដែលសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យមានសុវត្ថិភាពពីការឆ្លងរោគនៅក្នុងមន្ទីរពេទ្យ។

តាមរយៈការចូលរួម និងការប្តេជ្ញាចិត្តយ៉ាងមុតមាំពីសំណាក់លោកអ្នក មន្ទីរពេទ្យកុមារអង្គរបន្តអភិវឌ្ឍ និងពង្រឹងបេសកកម្មរបស់យើងកាន់តែរឹងមាំថែមទៀត ក្នុងការផ្តល់នូវការថែទាំសុខភាពប្រកបដោយគុណភាព និងដោយក្តីមេត្តាករុណាជូនដល់កុមារគ្រប់រូបនៅកម្ពុជា។



ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ

សាររបស់សាស្ត្រាចារ្យវេជ្ជបណ្ឌិត ងួន ច័ន្ទភក្ត្រា

ទិន្នន័យឆ្នាំ២០២៥

សូចនាកររាស់វែងសកម្មភាពអនុវត្តការងារឆ្នាំ២០២៥

**ការអភិវឌ្ឍថ្មីៗក្នុងឆ្នាំ២០២៥**

ការបោះជំហានឆ្ពោះទៅមុខរបស់មន្ទីរពេទ្យកុមារអង្គរ

ការលើកកម្ពស់សម្រាប់អនាគតជំនាន់ក្រោយ

អបអរសាទរដល់អ្នកផ្ដល់ប្រឹក្សាក្នុងឆ្នាំ២០២៥

ជួបជាមួយវេជ្ជបណ្ឌិតបញ្ចប់ការសិក្សារបស់យើង

ព្រឹត្តិការណ៍ធំៗរបស់មន្ទីរពេទ្យកុមារអង្គរ

អភិបាលកិច្ច

របាយការណ៍ហិរញ្ញវត្ថុ

សេចក្ដីថ្លែងអំណរគុណ




# ការជួសជុលដំបូល











តាមរយៈមូលនិធិ **YP Foundation** ដែលជាដៃគូឧបត្ថម្ភគាំទ្រដ៏ធំមួយរបស់មន្ទីរពេទ្យកុមារអង្គរ យើងបានសម្រេចកិច្ចការជួសជុល និងកែលម្អដំបូលនៅអគារផ្នែកចក្ខុរោគ ផ្នែកព្យាបាលដោយចលនា និងផ្នែកសង្គមកិច្ចវេជ្ជសាស្ត្រ នៅពាក់កណ្តាលខែវិច្ឆិកា ឆ្នាំ២០២៥។

ការជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធនេះបានផ្តល់នូវសុវត្ថិភាព អនាម័យស្អាត និងជួយជម្រុញសេវាថែទាំកាន់តែប្រសើរ។

គម្រោងខាងលើនេះក៏រួមបញ្ចូលទាំងការរៀបចំឡើងវិញនៃប្រព័ន្ធ អគ្គិសនីដែលមានដូចជា ការដំឡើងភ្លើងបំភ្លឺ និងបំពាក់កង្ហារបន្ថែម ដើម្បីកែលម្អខ្យល់ចេញចូល និងផាសុកភាពសម្រាប់គ្រួសារអ្នកជំងឺ។

ចំពោះក្រុមគ្រួសារជាច្រើនដែលធ្វើដំណើរពីខេត្តផ្សេង ឬតំបន់ជនបទ ហើយតម្រូវឲ្យស្នាក់នៅមន្ទីរពេទ្យក្នុងអំឡុងពេលព្យាបាលកូនរបស់ពួកគេ ជារឿយៗពួកគេមិនមានថវិកាគ្រប់គ្រាន់នោះទេដើម្បីស្នាក់នៅផ្ទះសំណាក់ ឬសណ្ឋាគារ។

ដូច្នេះហើយដំបូលដែលបានកែលម្អថ្មីនេះគឺបានក្លាយជាដំបូលសម្រាកដ៏ប្រសើរមួយសម្រាប់ក្រុមគ្រួសារអ្នកជំងឺដែលស្នាក់នៅបណ្តោះអាសន្ន ដើម្បីរងចាំទទួលការព្យាបាល។

# កៅអីពេទ្យធ្មេញថ្មី

ជាទូទៅអាគារជំងឺមាត់ធ្មេញ គឺជាផ្នែកមួយដែលមមាញឹកបំផុតនៅក្នុងមន្ទីរពេទ្យកុមារអង្គរ។ អាគារជំងឺមាត់ធ្មេញ បានជួយផ្តល់ការព្យាបាល និងថែទាំដល់កុមារដែលមានបញ្ហា ឬជំងឺសុខភាពមាត់ធ្មេញ ចន្លោះពី ៨០០ ដល់ ១០០០នាក់ ជារៀងរាល់ខែ។ ធៀបជាមួយនឹងចំនួនអ្នកជំងឺដ៏ច្រើនបែបនេះ ការប្រើប្រាស់ឧបករណ៍ដែលមានគុណភាព គឺមានសារៈសំខាន់ខ្លាំងណាស់ក្នុងការធានាថាកុមារនឹងទទួលបានការព្យាបាលទាន់ពេលវេលា សុវត្ថិភាព និងមានប្រសិទ្ធភាព។

មន្ទីរពេទ្យកុមារអង្គរ សូមថ្លែងអំណរគុណដល់ វេជ្ជបណ្ឌិត ខាធើរីន ម៉ៃឃលចន (Katherine Meiklejohn) ដែលមិនត្រឹមតែបានចូលរួមស្ម័គ្រចិត្តក្នុងសកម្មភាពចុះពិនិត្យ និងព្យាបាលសុខភាពមាត់ធ្មេញរបស់មន្ទីរពេទ្យកុមារអង្គរនៅសហគមន៍ប៉ុណ្ណោះទេ ប៉ុន្តែគាត់ក៏បានចូលរួមបរិច្ចាគកៅអីពេទ្យធ្មេញថ្មីមួយ ដើម្បីជួយពង្រឹងសេវាកម្មថែទាំមាត់ធ្មេញរបស់យើងឲ្យកាន់តែប្រសើរបន្ថែមទៀត។

*"កៅអីពេទ្យធ្មេញថ្មីនេះ ពិតជាបានជួយសម្រួលកិច្ចការជាច្រើននៅក្នុងផ្នែករបស់យើង។ កៅអីពេទ្យធ្មេញថ្មីនេះមានសុវត្ថិភាព រហ័ស និងមានភាពងាយស្រួលក្នុងការប្រើជាប្រចាំថ្ងៃ។ យើងប្រើប្រាស់កៅអីពេទ្យធ្មេញចាស់អស់រយៈពេលជាច្រើនឆ្នាំមកហើយ ប៉ុន្តែជារឿយៗវាតែងតែខូច ដែលរំខានដល់ការងារ និងត្រូវពន្យារពេលព្យាបាលអ្នកជំងឺ។"*

**អ្នកនាងវេជ្ជបណ្ឌិត ប៊ូ ណារ៉ែន**
**នាយផ្នែកជំងឺមាត់ធ្មេញរបស់មន្ទីរពេទ្យកុមារអង្គរ**

ការបរិច្ចាគនេះបង្ហាញពីសារៈសំខាន់របស់អ្នកស្ម័គ្រចិត្ត ក្នុងការចូលរួមពង្រឹងសេវាថែទាំសុខភាពកុមារនៅក្នុងប្រទេសកម្ពុជា។



# គម្រោងរៀបចំផ្ទះបាយថ្មី

នាចុងខែឧសភា ឆ្នាំ២០២៥ គម្រោងជួសជុលផ្ទះបាយត្រូវបានបញ្ចប់ដោយជោគជ័យ ដោយមានការផ្លាស់ប្តូរពីផ្ទះបាយចាស់ទៅជាផ្ទះបាយដែលមានកន្លែងចម្អិនអាហារ និងកន្លែងរក្សាទុកអាហារឆ្អិនដាច់ដោយឡែកពីគ្នា។ ផ្ទះបាយថ្មីនេះ បានផ្តល់នូវបរិយាកាសស្អាត មានអនាម័យ សុវត្ថិភាពចំណីអាហារ ដល់ក្រុមការងារផ្នែកអាហាររូបត្ថម្ភរបស់យើង ក្នុងការចម្អិនអាហារជូនដល់អ្នកជំងឺ។

លើសពីការផ្តល់អាហារូបត្ថម្ភដល់អ្នកជំងឺ និងការចែកកញ្ចប់អាហារដល់គ្រួសារអ្នកជំងឺ ក្រុមអាហារូបត្ថម្ភរបស់មន្ទីរពេទ្យ ក៏មានវគ្គបង្ហាញរបៀបចម្អិនអាហារសម្រាប់អ្នកជំងឺដល់អាណាព្យាបាលផងដែរ ដើម្បីឱ្យពួកគេទទួលបានចំណេះដឹង និងយល់កាន់តែច្បាស់អំពីសារៈសំខាន់នៃអាហារូបត្ថម្ភសម្រាប់ជួយការជាសះស្បើយកាន់តែរហ័ស និងរៀនពីរបៀបរៀបចំអាហារឲ្យសមស្របក្នុងអំឡុងពេលព្យាបាល និងក្រោយពេលត្រឡប់មកផ្ទះវិញ។

ផ្ទះបាយថ្មី ក៏បានផ្តល់នូវកន្លែងសម្រាប់ក្រុមគ្រួសារអ្នកជំងឺអាចចម្អិនអាហារដោយខ្លួនឯង។ គម្រោងខាងលើបានជួយដល់ក្រុមគ្រួសារជាច្រើនកាត់បន្ថយការចំណាយប្រចាំថ្ងៃ អំឡុងពេលដែលកូនៗរបស់ពួកគេកំពុងទទួលការព្យាបាលនៅមន្ទីរពេទ្យ។ សូមអរគុណដល់មូលនិធិ **Herbalife Family Foundation** សម្រាប់ការជួយគាំទ្រដ៏មានអត្ថន័យនេះ។











# ឧបករណ៍ឆ្លុះទងសួត និងឧបករណ៍វាស់ដង្ហើមថ្មី

ក្នុងឆ្នាំ២០២៥ ផ្នែកជំងឺផ្លូវដង្ហើមកុមាររបស់មន្ទីរពេទ្យកុមារអង្គរ បានធ្វើការអភិវឌ្ឍលើចំនុចសំខាន់ៗជាច្រើន។ ដោយក្នុងឆ្នាំ២០២៥ ពួកយើងបានទទួលឧបករណ៍សម្រាប់ធ្វើរោគវិនិច្ឆ័យផ្លូវដង្ហើមសំខាន់ៗចំនួនពីរ។ ទីមួយជាឧបករណ៍សម្រាប់ឆ្លុះទងសួតថ្មី និងទីពីរគឺឧបករណ៍វាស់ដង្ហើមថ្មី។ ឧបករណ៍ទំនើបទាំងពីរនេះបានជួយជម្រុញ និងផ្លាស់ប្តូរការពិនិត្យ ថែទាំដល់កុមារដែលមានបញ្ហាឬជំងឺផ្លូវដង្ហើមឲ្យកាន់តែប្រសើរឡើង។

ដោយមានជំនួយពីឧបករណ៍ឆ្លុះទងសួតថ្មី ក្រុមវេជ្ជបណ្ឌិតរបស់យើងអាចពន្លឿន និងពង្រឹងសមត្ថភាពក្នុងការធ្វើរោគវិនិច្ឆ័យ និងតាមដានស្ថានភាពជំងឺផ្លូវដង្ហើមដែលមានលក្ខណៈស្រួចស្រាវ និងស្មុគស្មាញបានដោយងាយស្រួល។

*“បើគ្មានជំនួយពីឧបករណ៍ឆ្លុះទងសួតថ្មីនេះទេ យើងនឹងមិនដឹងពីភាពមិនប្រក្រតី ឬបញ្ហាពិតប្រាកដនៅក្នុងផ្លូវដង្ហើមរបស់អ្នកជំងឺបានឡើយ។ ការធ្វើរោគវិនិច្ឆ័យបានត្រឹមត្រូវអនុញ្ញាតឱ្យយើងអាចផ្តល់ការព្យាបាលបានកាន់តែប្រាកដ ឆាប់រហ័ស និងកាត់បន្ថយការព្រួយបារម្ភរបស់ឪពុកម្តាយ។”*

**អ្នកស្រីវេជ្ជបណ្ឌិត គង់ សុខចិន្តា**
**នាយផ្នែកជំងឺផ្លូវដង្ហើមកុមាររបស់មន្ទីរពេទ្យកុមារអង្គរ**

ជាមួយគ្នានេះដែរ ឧបករណ៍វាស់ដង្ហើមថ្មីនេះ ផ្តល់សារៈសំខាន់ក្នុងកិច្ចប្រតិបត្តិការប្រចាំថ្ងៃនៅក្នុងផ្នែកព្យាបាលជំងឺផ្លូវដង្ហើមកុមារ ដោយជួយសម្រួលលើការពិនិត្យ និងធ្វើរោគវិនិច្ឆ័យដល់អ្នកជំងឺផ្លូវដង្ហើមប្រមាណ ១៥០ នាក់ជារៀងរាល់ខែ។








# បណ្ណាល័យចល័ត

នៅមន្ទីរពេទ្យកុមារអង្គរ ក្រៅពីការផ្តល់ការព្យាបាលលើផ្នែកវេជ្ជសាស្ត្រ យើងក៏ផ្តល់ការយកចិត្តទុកដាក់ និងថែទាំលើអ្នកជំងឺលើសពីការព្យាបាលផងដែរ។ នាខែធ្នូ ឆ្នាំ២០២៥ មន្ទីរពេទ្យកុមារអង្គរ បានដាក់ឱ្យដំណើរការនូវកម្មវិធីបណ្ណាល័យចល័ត ដែលជាផ្នែកមួយនៃការថែទាំសុខភាពរបស់យើងក្នុងគោលបំណងជួយផ្តល់ការកំសាន្ត បែបអប់រំ និងផ្តល់ភាពរីករាយដល់កុមារ និងក្រុមគ្រួសាររបស់ពួកគេដែលរង់ចាំទទួលការពិនិត្យព្យាបាលនៅមន្ទីរពេទ្យ។

បណ្ណាល័យចល័តរបស់យើង មិនត្រឹមតែផ្តល់ភាពសប្បាយរីករាយដល់កុមារនោះទេ តែវាជួយបង្កើតបរិយាកាសសមស្របមួយដែលចូលរួមគាំទ្រដល់សុខុមាលភាពផ្លូវចិត្តរបស់កុមារ និងក្រុមគ្រួសាររបស់ពួកគេក្នុងពេលវេលាដ៏តានតឹងផងដែរ។

តាមរយៈការឧបត្ថម្ភគាំទ្រពីមូលនិធិ YP Foundation និង ឌីជេ ណាណា ក្រុមការងារផ្នែកសង្គមកិច្ចរបស់យើង បាននាំមកនូវបណ្ណាល័យចល័ត ដែលពេញដោយសៀវភៅកុមារ ឧបករណ៍ក្មេងលេង សៀវភៅរឿងនិទាន សៀវភៅផាត់ពណ៌ និងសំភារៈផ្សេងៗជាច្រើនទៀតសម្រាប់កុមារនៅគ្រប់អាគារអ្នកជំងឺទាំងអស់។



ស្កេនយូអរដើម្បីទស្សនាវីដេអូខ្លីអំពីបណ្ណាល័យចល័តរបស់យើង

ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ

សាររបស់សាស្ត្រាចារ្យវេជ្ជបណ្ឌិត ងួន ច័ន្ទភក្ត្រា

ទិន្នន័យឆ្នាំ២០២៥

សូចនាកររាស់វែងសកម្មភាពអនុវត្តការងារឆ្នាំ២០២៥

ការអភិវឌ្ឍថ្មីៗក្នុងឆ្នាំ២០២៥

**ការបោះជំហានឆ្ពោះទៅមុខរបស់មន្ទីរពេទ្យកុមារអង្គរ**

ការលើកកម្ពស់សម្រាប់អនាគតជំនាន់ក្រោយ

អបអរសាទរដល់អ្នកផ្តល់ប្រឹក្សាក្នុងឆ្នាំ២០២៥

ជួបជាមួយវេជ្ជបណ្ឌិតបញ្ចប់ការសិក្សារបស់យើង

ព្រឹត្តិការណ៍ធំៗរបស់មន្ទីរពេទ្យកុមារអង្គរ

អភិបាលកិច្ច

របាយការណ៍ហិរញ្ញវត្ថុ

សេចក្តីថ្លែងអំណរគុណ




# អស្ថិរភាពនៅតាមតំបន់ព្រំដែន



ចាប់ពីខែកក្កដា រហូតដល់ខែធ្នូ ឆ្នាំ២០២៥ ការប៉ះទង្គិចគ្នាដោយប្រដាប់អាវុធនៅតាមព្រំដែនរវាងកម្ពុជា និងសៀមបានធ្វើឱ្យប្រជាជនកម្ពុជាប្រមាណ ៤០០ ០០០នាក់ នៅតាមតំបន់ព្រំដែនខ្មែរ-សៀម ភៀសខ្លួនផ្លាស់ទីលំនៅ។ ខេត្តសៀមរាបបានរៀបចំទទួលក្រុមគ្រួសារភៀសសឹកមួយចំនួនធំពីខេត្តជាប់ព្រំដែនទាំងបី ដែលមានខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ និងខេត្តបន្ទាយមានជ័យ។ ភាគច្រើននៃជនភៀសសឹកជាមនុស្សចាស់ និងកុមារ។

ដោយមានការសហការជាមួយអ្នករៀបចំទទួលក្រុមគ្រួសារភៀសសឹកនៅតាមសហគមន៍ ក្រុមការងាររបស់យើង អាចប្រមូលផ្តុំជនរងគ្រោះ និងខ្វះខាតបំផុតបានយ៉ាងឆាប់រហ័ស។ ក្នុងរយៈពេលដ៏តានតឹងនេះ ក្រុមការងាររបស់មន្ទីរពេទ្យកុមារអង្គរ បានចុះធ្វើការដោយផ្ទាល់នៅតាមទីតាំងជម្រកភៀសសឹកនៅទូទាំងខេត្តសៀមរាប និងផ្តល់ការគាំទ្រលើការពិគ្រោះយោបល់ផ្នែកសុខភាព ពិនិត្យព្យាបាលជំងឺផ្សេងៗ និងបញ្ជូនអ្នកជំងឺមកមន្ទីរពេទ្យក្នុងករណីធ្ងន់ធ្ងរ។

តាមរយៈកិច្ចខិតខំប្រឹងប្រែងអស់រយៈពេលពីរសប្តាហ៍ ក្នុងខែសីហា រហូតដល់ខែធ្នូ ក្រុមការងារសហគមន៍របស់យើង រួមជាមួយគិលានុបដ្ឋាក និងវេជ្ជបណ្ឌិតស្ម័គ្រចិត្ត បានផ្តល់ការពិគ្រោះយោបល់ និងការពិនិត្យសុខភាពដល់ពលរដ្ឋភៀសសឹកចំនួន **២ ៩៧៨ ករណី** និងបានផ្តល់ការអប់រំសុខភាពដល់អ្នកចូលរួមចំនួន **៥ ៩៥៥នាក់**។

កិច្ចការងារដ៏មានសារៈសំខាន់សម្រាប់ជនរួមជាតិខ្មែរនេះ គឺជាចំណែកចូលរួមសម្រួល និងជួយធានាថាក្រុមគ្រួសារកុមារដែលយើងបានគាំទ្រ ជាពិសេសកុមារងាយរងគ្រោះ និងមនុស្សចាស់ អាចទទួលបានព័ត៌មានសំខាន់ៗអំពីការថែទាំសុខភាព និងអនាម័យក្នុងអំឡុងពេលដ៏លំបាកបំផុតនេះ។

*(ប្រភព៖ Kiripost, 2025)*

# ការព្យាបាលថែទាំសុខភាព អំឡុងពេលអស្ថិរភាពព្រំដែន



កុមារាសីហា និងក្រុមគ្រួសារនៅវត្តចារឈូក (ចំងាយប្រហែល ៥០ គីឡូម៉ែត្រពីក្រុងសៀមរាប)

កុមារាសីហា និងក្រុមគ្រួសារកុមារតូចនេះបាន រត់ភៀសខ្លួនចេញពីភូមិឋានរបស់ពួកគេដែលស្ថិត នៅក្នុងខេត្តបន្ទាយមានជ័យ ដើម្បីមកស្នាក់នៅ ជម្រកបណ្តោះអាសន្ននៅវត្តចារឈូក ខេត្ត សៀមរាប។ ដោយសារមានជំងឺហឺតធ្វើឲ្យគាត់ ចាប់ ផ្តើមមានអាការៈពិបាកដកដង្ហើម ក្នុងអំឡុងពេល ស្នាក់នៅជម្រកជនភៀសសឹក។

អំឡុងពេលចុះបេសកកម្មអប់រំសុខភាព និងសង្គ្រោះ ក្រុមគ្រូពេទ្យរបស់មន្ទីរពេទ្យកុមារអង្គរ បានវាយតម្លៃ ស្ថានភាពរបស់សីហាយ៉ាងឆាប់រហ័ស និងបានផ្តល់ ការព្យាបាលដោយប្រើម៉ាស៊ីនផ្លុង ដែលជួយសម្រួល ដល់ការដកដង្ហើមរបស់គាត់។

**ម្តាយរបស់សីហា បានឲ្យដឹងថា៖**

*"ពេលមានរឿង យើងរត់ភៀសខ្លួនមកភ្លាមដោយមិន បានត្រៀមអ្វីមុនទេ សូម្បីតែម៉ាស៊ីនផ្លុងរបស់កូនខ្ញុំ។ នៅពេលដែលមានក្រុមគ្រូពេទ្យចុះមកជួយពិនិត្យឲ្យ កូនខ្ញុំ ខ្ញុំមានអារម្មណ៍ធូស្បើយជាងមុន ព្រោះយ៉ាងហោចណាស់កូនរបស់ខ្ញុំអាចទទួលបាន សេវាព្យាបាលត្រឹមត្រូវមួយ"*



# ការពង្រីកវិសាលភាពនៃកម្មវិធីសង្គ្រោះទារក



ដោយផ្អែកលើការអនុវត្តគម្រោងបានដោយជោគជ័យនៅខេត្តព្រះវិហារ ក្នុងឆ្នាំ២០២៥ **កម្មវិធីសង្គ្រោះទារក**បានពង្រីកខ្លួន និងបន្តបេសសកម្មមកដល់ក្នុងស្រុកប្រតិបត្តិអង្គរជុំ និងនៅសហគមន៍ជនបទមួយចំនួននៅស្រុកចំនួនបីក្នុងខេត្តសៀមរាប។

ឆ្នាំទីមួយនៃការអនុវត្តគម្រោង ក្រុមការងារនៃកម្មវិធីសង្គ្រោះទារក បានរៀបចំ និងដំឡើងឧបករណ៍សង្គ្រោះជីវិតទារក នៅក្នុងមណ្ឌលសុខភាពចំនួន ៤ និងនៅមន្ទីរពេទ្យបង្អែកស្រុកចំនួន ១ រួមជាមួយការផ្តល់ការបណ្តុះបណ្តាល និងការណែនាំដល់អ្នកជំនាញសុខភាពចំនួន ៤២៥នាក់ ដែលមកពីមណ្ឌលសុខភាពចំនួន ១១។

កម្មវិធីសង្គ្រោះទារករបស់យើង នឹងបន្តបេសសកម្មទៅកាន់មណ្ឌលសុខភាពចំនួន ២៣ និងមន្ទីរពេទ្យបង្អែកស្រុកចំនួន ២ បន្ថែមទៀតតាមគម្រោងដែលបានគ្រោងទុក ដោយក្រុមការងាររបស់យើងនឹងប្តេជ្ញាចិត្តថា ជួយការបណ្តុះបណ្តាល និងការណែនាំដល់អ្នកជំនាញសុខភាព និងផ្តល់សំភារៈ ឧបករណ៍ដែលចាំបាច់ ដើម្បីជួយសង្គ្រោះដល់ទារកទើបនឹងកើតគ្រប់រូបឲ្យជៀសផុតពីគ្រោះថ្នាក់។

# ការកសាងសមត្ថភាពដើម្បីជួយសង្គ្រោះជីវិត



## អ្នកគ្រូពេទ្យ រ៉ានី

### គិលានុបដ្ឋាយិកា នៅមណ្ឌលសុខភាពតាសោម

*“តាមរយៈវគ្គបណ្តុះបណ្តាលរបស់ក្រុមការងារកម្មវិធីសង្គ្រោះទារក បានផ្តល់បទពិសោធន៍ដ៏ល្អ និងចំណេះដឹងជាច្រើនសម្រាប់ខ្ញុំ។ ទោះបីជាបានធ្វើការជាគិលានុបដ្ឋាយិកាអស់រយៈពេលយូរមកហើយក៏ដោយសម្រាប់ខ្ញុំ ខ្ញុំនៅតែរៀនសូត្របានទូវចំណេះដឹងថ្មី ដែលខ្ញុំមិនធ្លាប់ដឹងពីមុនមក។ ក្នុងវគ្គបណ្តុះបណ្តាលផ្ទាល់ យើងក៏ទទួលបានបទពិសោធន៍ជាក់ស្តែង និងអនុវត្តផ្ទាល់ ដោយមានគ្រូបង្វឹកជួយណែនាំ និងជួយកែតម្រូវយើងភ្លាមៗ”*

ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ

សាររបស់សាស្ត្រាចារ្យវេជ្ជបណ្ឌិត ដួន ច័ន្ទភក្ត្រា

ទិន្នន័យឆ្នាំ២០២៥

សូចនាកររាស់វែងសកម្មភាពអនុវត្តការងារឆ្នាំ២០២៥

ការអភិវឌ្ឍថ្មីៗក្នុងឆ្នាំ២០២៥

ការបោះជំហានឆ្ពោះទៅមុខរបស់មន្ទីរពេទ្យកុមារអង្គរ

**ការលើកកម្ពស់សម្រាប់អនាគតជំនាន់ក្រោយ**

អបអរសាទរដល់អ្នកផ្តល់ប្រឹក្សាក្នុងឆ្នាំ២០២៥

ជួបជាមួយវេជ្ជបណ្ឌិតបញ្ចប់ការសិក្សារបស់យើង

ព្រឹត្តិការណ៍ធំៗរបស់មន្ទីរពេទ្យកុមារអង្គរ

អភិបាលកិច្ច

របាយការណ៍ហិរញ្ញវត្ថុ

សេចក្តីថ្លែងអំណរគុណ





មន្ទីរពេទ្យកុមារអង្គរ គឺជាមន្ទីរពេទ្យដែលផ្តល់ការបណ្តុះបណ្តាលអប់រំដ៏សំខាន់ សម្រាប់អ្នកជំនាញសុខាភិបាលនៅប្រទេសកម្ពុជា និងអន្តរជាតិ។ ជារៀងរាល់ឆ្នាំ មន្ទីរពេទ្យកុមារអង្គរទទួលស្វាគមន៍គិលានុបដ្ឋាក ឆ្មប វេជ្ជបណ្ឌិត និងអ្នកស្ម័គ្រចិត្ត រាប់រយនាក់ ដើម្បីទទួលការបណ្តុះបណ្តាល ចែករំលែកបទពិសោធន៍ និងជំនាញ បច្ចេសទេសផ្សេងៗដែលផ្តោតលើការអភិវឌ្ឍការព្យាបាលថែទាំ។

ក្រៅពីការអភិវឌ្ឍលើផ្នែកវេជ្ជសាស្ត្រ មន្ទីរពេទ្យកុមារអង្គរ ក៏បានលើកកម្ពស់ចំណេះដឹង ការណែនាំ និងការអភិវឌ្ឍវិជ្ជាជីវៈផ្សេងៗបន្ថែម ដែលផ្តល់ឱ្យនិស្សិតហ្វឹកហាត់ អាចពង្រឹងជំនាញ និងយកទៅអនុវត្ត ចែករំលែកបន្តនៅស្ថាប័នរបស់ពួកគេបាន ដោយមានទំនុកចិត្ត និងប្រកបដោយក្តីមេត្តាករុណា ដើម្បីលើកស្ទួយប្រព័ន្ធថែទាំសុខភាពកុមារនៅទូទាំងប្រទេសកម្ពុជា។

ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ

សាររបស់សាស្ត្រាចារ្យវេជ្ជបណ្ឌិត ងួន ច័ន្ទភក្រ្តា

ទិន្នន័យឆ្នាំ២០២៥

សូចនាកររាស់វែងសកម្មភាពអនុវត្តការងារឆ្នាំ២០២៥

ការអភិវឌ្ឍថ្មីៗក្នុងឆ្នាំ២០២៥

ការបោះជំហានឆ្ពោះទៅមុខរបស់មន្ទីរពេទ្យកុមារអង្គរ

ការលើកកម្ពស់សម្រាប់អនាគតជំនាន់ក្រោយ

**អបអរសាទរដល់អ្នកផ្តល់ប្រឹក្សាក្នុងឆ្នាំ២០២៥**

ជួបជាមួយវេជ្ជបណ្ឌិតបញ្ចប់ការសិក្សារបស់យើង

ព្រឹត្តិការណ៍ធំៗរបស់មន្ទីរពេទ្យកុមារអង្គរ

អភិបាលកិច្ច

របាយការណ៍ហិរញ្ញវត្ថុ

សេចក្តីថ្លែងអំណរគុណ



ជារៀងរាល់ឆ្នាំ អ្នកជំនាញវេជ្ជសាស្ត្រស្ម័គ្រចិត្តមកពីជុំវិញពិភពលោក បានចែករំលែកចំណេះដឹងថ្មីៗ និងអភិវឌ្ឍជំនាញបច្ចេកទេសដល់ក្រុមវេជ្ជបណ្ឌិតរបស់យើង ក្នុងគោលបំណងលើកកម្ពស់ប្រព័ន្ធថៃទាំសុខភាពកុមារនៅប្រទេសកម្ពុជាឲ្យកាន់តែប្រសើរឡើង។ ក្នុងឆ្នាំនេះ យើងសូមធ្វើការណែនាំឲ្យស្គាល់លោកវេជ្ជបណ្ឌិត **រីឆាត ហេនឃើរ** (Richard Henker) ក្នុងនាមជាសាស្ត្រាចារ្យណែនាំនៃផ្នែករះកាត់។



## វេជ្ជ. រីឆាត ហេនឃើរ

**វេជ្ជបណ្ឌិតឯកទេសថ្នាំសណ្ដំ**

“វាជាកិត្តិយសដ៏ធំធេងសម្រាប់ខ្ញុំ ហើយក៏ជាពេលវេលាដែលមិនអាចបំភ្លេចបានដែលបានរួមការងារជាមួយក្រុមការងារផ្នែកវះកាត់នៅទីនេះ។

អំឡុងពេលបំពេញការងារស្ម័គ្រចិត្តរបស់ខ្ញុំនៅមន្ទីរពេទ្យកុមារអង្គរ បានរំលឹកខ្ញុំថា ការព្យាបាលថែទាំកុមារដ៏ល្អឥតខ្ចោះ មិនមែនពឹងផ្អែកតែលើជំនាញវេជ្ជសាស្ត្រតែមួយប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ត្រូវការក្តីមេត្តាករុណា មនុស្សធម៌ ការអត់ធ្មត់ និងការខិតខំប្រឹងប្រែងរួមគ្នាផងដែរ។

ការពិភាក្សា ការជជែកវែកញែក និងអន្តរកម្មនីមួយៗ បានឆ្លុះបញ្ចាំងពីសេចក្តីថ្លៃថ្នូរ កិច្ចសហការ និងផ្តល់ការគោរពក្នុងក្រុមការងាររបស់យើង។”

ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ
សាររបស់សាស្ត្រាចារ្យវេជ្ជបណ្ឌិត ងួន ច័ន្ទភក្ត្រា
ទិន្នន័យឆ្នាំ២០២៥
សូចនាករវាស់វែងសកម្មភាពអនុវត្តការងារឆ្នាំ២០២៥
ការអភិវឌ្ឍថ្មីៗក្នុងឆ្នាំ២០២៥
ការបោះជំហានឆ្ពោះទៅមុខរបស់មន្ទីរពេទ្យកុមារអង្គរ
ការលើកកម្ពស់សម្រាប់អនាគតជំនាន់ក្រោយ
អបអរសាទរដល់អ្នកផ្តល់ប្រឹក្សាក្នុងឆ្នាំ២០២៥
**ជួបជាមួយវេជ្ជបណ្ឌិតបញ្ចប់ការសិក្សារបស់យើង**
ព្រឹត្តិការណ៍ធំៗរបស់មន្ទីរពេទ្យកុមារអង្គរ
អភិបាលកិច្ច
របាយការណ៍ហិរញ្ញវត្ថុ
សេចក្តីថ្លែងអំណរគុណ



យើងមានមោទនភាព និងចូលរួមអបអរសាទរដល់វេជ្ជបណ្ឌិតហ្វឹកហាត់ចំនួន **៦នាក់** បានបញ្ចប់វគ្គបណ្តុះបណ្តាលផ្នែកជំងឺកុមាររយៈពេល ១ឆ្នាំ។ ក្នុងចំណោមនោះ មានវេជ្ជបណ្ឌិត ៣រូប បានជ្រើសរើសបន្តបម្រើការងារឯកទេសនៅមន្ទីរពេទ្យកុមារអង្គរ។ ឫង វេជ្ជបណ្ឌិតដទៃបានចាកចេញ និងបន្តជំនាញរបស់ពួកគេក្នុងនាមជាវេជ្ជបណ្ឌិតជាមួយនឹងបទពិសោធន៍ ជំនាញ ក្តីមេត្តាករុណា និងគុណតម្លៃដែលបានរៀនសូត្រនៅមន្ទីរពេទ្យកុមារអង្គរ។

# ជួបជាមួយវេជ្ជបណ្ឌិតឯកទេសភ្នែកកុមារ



វេជ្ជបណ្ឌិត លី សុគន្ធា

"

*ក្នុងនាមជាគ្រូពេទ្យភ្នែកម្នាក់ ខ្ញុំសប្បាយចិត្តនៅពេល ឃើញកែវភ្នែកកុមារមានសុខភាពល្អ និងគ្រប់លក្ខណៈ។*

*ខ្ញុំរឹតតែសប្បាយចិត្តនៅពេលឃើញពួកគាត់មានគំហើញក្នុងការមើលល្អ។ កុមារគ្រប់រូបសមនឹងទទួលបានឱកាសមើលឃើញភាពស្រស់ស្អាតនៃពិភពលោកមួយនេះ។ តាមរយៈជំនាញនេះ ខ្ញុំសង្ឃឹមថាកុមារគ្រប់រូប គួរតែមានឱកាសការទទួលបានការព្យាបាលដ៏ត្រឹមត្រូវ ដើម្បីជួយនិងស្តារគំហើញរបស់ពួកគេ។*

"

# ជួបជាមួយវេជ្ជបណ្ឌិតឯកទេសថ្នាំសណ្ដំ

“កាលខ្ញុំធ្វើការនៅផ្នែកសង្គ្រោះបន្ទាន់ ខ្ញុំបានឃើញអ្នកជំងឺរបួសបញ្ជូនទៅក្នុងបន្ទប់វះកាត់ ហើយត្រឡប់មកវិញដោយគ្មានការឈឺចាប់ និងអាចបរិភោគធម្មតា។

ចំពោះខ្ញុំផ្ទាល់ ខ្ញុំយល់ថាវាពិតជាអស្ចារ្យណាស់។ មូលហេតុដែលខ្ញុំចង់ក្លាយជាវេជ្ជបណ្ឌិតឯកទេសខាងថ្នាំសណ្ដំ គឺការបានជួយអ្នកជំងឺឱ្យបានជាសះស្បើយ និង ត្រឡប់ទៅប្រើជីវិតធម្មតារបស់ពួកគេវិញដោយគ្មានការឈឺចាប់បន្ទាប់ពីការវះកាត់។”



វេជ្ជបណ្ឌិត ឈុំ មានភ័ព្វ

# ជួបជាមួយវេជ្ជបណ្ឌិត
# បញ្ចប់ការសិក្សារបស់យើង



## វេជ្ជបណ្ឌិត រ៉ុន ដាលីន

**វេជ្ជបណ្ឌិតបណ្ដុះបណ្ដាលផ្នែកជំងឺធ្ងន់ និងសង្គ្រោះបន្ទាន់**

“ការហ្វឹកហាត់ រៀនសូត្រនៅផ្នែកជំងឺធ្ងន់ និងសង្គ្រោះបន្ទាន់ បានបង្រៀនខ្ញុំពីភាពអត់ធន់ របៀបធ្វើការជាក្រុម និងការសម្រេចចិត្តក្រោមសម្ពាធ។ នៅទីនេះ គ្រប់សកម្មភាពនីមួយៗ ទាមទារមានការគិតច្បាស់លាស់ រហ័ស និងក្ដីមេត្តាករុណា។ ក្នុងផ្នែកនេះ ខ្ញុំឃើញជីវិតរបស់កុមារប្រឈមនឹងគ្រោះថ្នាក់ និងផុយស្រួយណាស់ ប៉ុន្តែការយកចិត្តទុកដាក់  និងការជឿទុកចិត្តអាចជួយធ្វើឱ្យមានភាពប្រសើរឡើងច្រើននៅក្នុងគ្រាដ៏អាសន្ន ”



## វេជ្ជបណ្ឌិត ឡេង សុធានិត

**វេជ្ជបណ្ឌិតបណ្ដុះបណ្ដាលជំនាញជំងឺសើរស្បែក**

“ជំងឺសើរស្បែកភាគច្រើនមិនបង្កអោយគ្រោះថ្នាក់ដល់អាយុជីវិតនោះទេ ប៉ុន្តែវាបានផ្ដល់ផលរំខានយ៉ាងខ្លាំងដល់ការលូតលាស់ជីវភាពប្រចាំថ្ងៃ ក៏ដូចជាការសិក្សា និងផ្លូវចិត្តសង្គមរបស់កុមារ។ ក្នុងនាមជាគ្រូពេទ្យសើរស្បែកម្នាក់ខ្ញុំសង្ឃឹមថាកុមារគ្រប់រូប នឹងទទួលបានការព្យាបាលជំងឺសើរស្បែក ដ៏ត្រឹមត្រូវប្រកបដោយប្រសិទ្ធភាព”



## វេជ្ជបណ្ឌិត អ៊ែ ធារ៉ានីដ

**វេជ្ជបណ្ឌិតបណ្ដុះបណ្ដាលជំនាញមីក្រុបវិទ្យា និង ជំងឺឆ្លងកុមារ**

“ការបណ្ដុះបណ្ដាលនៅមន្ទីរពិសោធន៍របស់មន្ទីរពេទ្យកុមារអង្គរ បានឲ្យខ្ញុំដឹងថា រាល់សំណាកជម្រើសថ្នាំអង់ទីប៊ីយោទិក និងសារពាង្គកាយដែលធន់នឹងថ្នាំនីមួយៗ វាប្រៀបដូចអនាគតរបស់កុមារអញ្ចឹង។ ខ្ញុំមានតួនាទីយ៉ាងសំខាន់ក្នុងការជួយដល់ក្រុមគ្រូពេទ្យសម្រេចចិត្តព្យាបាលទាន់ឲ្យពេលវេលា និងត្រឹមត្រូវ។ ការងាររបស់ខ្ញុំរួមចំណែកដល់ការប្រយុទ្ធប្រឆាំងនឹងភាពស៊ាំនឹងថ្នាំអង់ទីប៊ីយោទិក (AMR) ក្នុងពេលតែមួយយើងក៏ផ្ដល់ពីគុណភាពនៃការព្យាបាល និងសុខុមាលភាពរបស់កុមារផងដែរ”



**វេជ្ជបណ្ឌិត ច្រឹង ចាន់ភារ៉ា**

**វេជ្ជបណ្ឌិតកម្មសិក្សាជំនាញកុមារ**

“ខ្ញុំមានអារម្មណ៍រីករាយ និងកោតសរសើរយ៉ាងខ្លាំងចំពោះបរិយាកាសនៃកម្មវិធីសិក្សាដែលបង្កើនអោយមានការខិតខំប្រឹងប្រែង ការប្តេជ្ញាចិត្ត នៃវេជ្ជបណ្ឌិតផ្នែកជំងឺកុមារ។ អ្វីដែលធ្វើឱ្យខ្ញុំចាប់អារម្មណ៍ជាងនេះ គឺជាការយកចិត្តទុកដាក់របស់មន្ទីរពេទ្យកុមារអង្គរ ក្នុងកិច្ចអភិវឌ្ឍធនធានមនុស្សគ្រប់ផ្នែក ឱ្យមានសមត្ថភាពខ្ពស់ ដើម្បីផ្តល់ការថែទាំ និងព្យាបាលកុមារ ប្រកបដោយប្រសិទ្ធភាព”



**វេជ្ជបណ្ឌិត សុ ខា អារុណ**

**វេជ្ជបណ្ឌិតកម្មសិក្សាជំនាញកុមារ**

“រាប់តាំងពីផ្នែកពិគ្រោះជំងឺក្រៅ រហូតដល់ផ្នែកសម្រាកជំងឺ ផ្នែកជំងឺធ្ងន់ និងសង្គ្រោះបន្ទាន់ ផ្នែកថែទាំទារកទើបនឹងកើត និងរាល់ផ្នែកពិសោធន៍នីមួយៗនៅមន្ទីរពេទ្យកុមារអង្គរ បានជួយធ្វើឱ្យខ្ញុំក្លាយជាវេជ្ជបណ្ឌិតផ្នែកជំងឺកុមារដ៏រឹងមាំម្នាក់។ រាល់ការអប់រំ ការធ្វើការជាក្រុម និងការថែទាំដែលផ្តោតលើអ្នកជំងឺ បានជម្រុញទឹកចិត្តខ្ញុំឱ្យខិតខំដើម្បីទទួលបានការអភិវឌ្ឍឲ្យកាន់តែប្រសើរឡើង។ ខ្ញុំពិតជារីករាយដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ និងការប្តេជ្ញាចិត្តថា នឹងចូលរួមលើកកម្ពស់ការថែទាំសុខភាពរបស់កុមារ។”

*វេជ្ជបណ្ឌិតមួយរូបស្នើសូមមិនបញ្ចេញអត្តសញ្ញាណនៅក្នុងរបាយការណ៍នេះ*

ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ
សាររបស់សាស្ត្រាចារ្យវេជ្ជបណ្ឌិត ងួន ច័ន្ទភក្ត្រា
ទិន្នន័យឆ្នាំ២០២៥
សូចនាកររាស់វែងសកម្មភាពអនុវត្តការងារឆ្នាំ២០២៥
ការអភិវឌ្ឍថ្មីៗក្នុងឆ្នាំ២០២៥
ការបោះជំហានឆ្ពោះទៅមុខរបស់មន្ទីរពេទ្យកុមារអង្គរ
ការលើកកម្ពស់សម្រាប់អនាគតជំនាន់ក្រោយ
អបអរសាទរដល់អ្នកផ្តល់ប្រឹក្សាក្នុងឆ្នាំ២០២៥
ជួបជាមួយវេជ្ជបណ្ឌិតបញ្ចប់ការសិក្សារបស់យើង
**ព្រឹត្តិការណ៍ធំៗរបស់មន្ទីរពេទ្យកុមារអង្គរ**
អភិបាលកិច្ច
របាយការណ៍ហិរញ្ញវត្ថុ
សេចក្តីថ្លែងអំណរគុណ




ឆ្នាំនេះគឺជាឆ្នាំដ៏អស្ចារ្យមួយសម្រាប់មន្ទីរពេទ្យកុមារអង្គរ។ តាមរយៈការគាំទ្រដ៏ធំធេងរបស់អ្នកទាំងអស់គ្នា យើងបានកៀរគរថវិកាដោយជោគជ័យ ដើម្បីបន្តបេសកកម្មរបស់យើងទៅមុខទៀត។ ចាប់តាំងពីព្រឹត្តិការណ៍ដ៏មានកិត្យានុភាព «ជួបជាមួយស្ថាបនិក» (Meet the Founder) ដែលបាននាំមកនូវការជួបជុំអ្នកគាំទ្រដ៏ជិតស្និទ្ធបំផុត រហូតដល់រាត្រីសមោសរអន្តរជាតិ «អាហារពេលល្ងាចដ៏វិសេសវិសាល» (Dinner with a Difference) សេចក្តីសប្បុរសរបស់អ្នកទាំងអស់គ្នាបានបង្ហាញយ៉ាងច្បាស់ថា ការរួបរួមសាមគ្គីពិតជាផ្តល់នូវលទ្ធផលដ៏ធំធេងសម្រាប់កុមារនៅកម្ពុជា។



## ជួបជាមួយស្ថាបនិកមន្ទីរពេទ្យកុមារអង្គរ ឆ្នាំ២០២៥
**ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៥**

រាត្រីនៃការផ្តល់កិត្តិយស ការបង្ហាញពីលទ្ធផល និងការជួបជុំគ្នានៃសប្បុរសជនមន្ទីរពេទ្យកុមារអង្គរ។ យើងបានរៀបចំកម្មវិធីដ៏កក់ក្តៅមួយគឺ **«ជួបជាមួយស្ថាបនិកមន្ទីរពេទ្យកុមារអង្គរ»** ជាលើកទី៤ នៅសណ្ឋាគារ សាន់ អ៊ែន មូន រីវើសាយ។ វាគឺជាជំនួបជាមួយស្ថាបនិកជនជាតិជប៉ុនដ៏ល្បីល្បាញគឺ លោក ខិនរ៉ូ អ៊ីហ្ស៊ូ (Kenro Izu) និងសប្បុរសជនកម្ពុជាដែលមានបេះដូងមនុស្សធម៌ជួយគាំទ្រឱ្យមន្ទីរពេទ្យកុមារអង្គរ។

នៅចុងបញ្ចប់នៃកម្មវិធី យើងបានប្រមូលមូលនិធិចំនួន **៦៨ ៦៩១ ដុល្លារ** ពីការចូលរួមចំណែកដ៏ធំធេងនេះ។



## ពិធីបុណ្យផ្កាប្រាក់មហាសាមគ្គីឆ្នាំទី ១២
**ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២៥**

ចាប់តាំងពីឆ្នាំ ២០១៣ មក មន្ទីរពេទ្យ-កុមារអង្គរបានរៀបចំពិធីបុណ្យប្រពៃណី **«ពិធីបុណ្យផ្កាប្រាក់មហាសាមគ្គី»** ឱ្យក្លាយទៅជាសកម្មភាពមនុស្សធម៌ដើម្បីសេវាថែទាំសុខភាពកុមារកម្ពុជាដែលដឹកនាំ និងផ្តួចផ្តើមឡើងដោយសម្តេចព្រះព្រហ្មរតនមុនី **ពិន សែម** សិរីសុវណ្ណោ ព្រះរាជាគណៈថ្នាក់ទោ ឧត្តមទីប្រឹក្សាគណៈសង្ឃនាយក និងជាព្រះចៅអធិការ វត្តរាជបូណ៌។

ក្នុងឆ្នាំ២០២៥ ពិធីបុណ្យនេះបានរៃអង្គាសថវិកា **១៧៤ 000** ដុល្លារ។

ការជួយឧបត្ថម្ភគាំទ្រនេះធានាថាមន្ទីរពេទ្យកុមារអង្គរគឺជាមន្ទីរពេទ្យរបស់យើងទាំងអស់គ្នា និងដើម្បីសុខភាពកុមារកម្ពុជា។




## អាហារពេលល្ងាចដ៏វិសេសវិសាល
**ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥**

កម្មវិធីដ៏វិសេសវិសាលគឺ **«អាហារពេលល្ងាចដ៏វិសេសវិសាល»** បានត្រឡប់មកវិញ។ នៅក្នុងកម្មវិធីនេះ មានការចូលរួមពីសប្បុរសជនដ៏មានចិត្តសប្បុរសចំនួន ៧០រូប នៅក្លឹបវាយកូនហ្គោល Sentosa Golf Pavilion ប្រទេសសាំងហ្គាពួរ។ ជាមួយគ្នានេះផងដែរ លោកវេជ្ជបណ្ឌិត ឡេង ណារ៉ា នៃមជ្ឈមណ្ឌលរបួសធ្ងន់ និងរបួសប៉ះទង្គិច ក៏បានចែករំលែកអំពីសកម្មភាពការងារ និងការជួយសង្គ្រោះជីវិតកុមារជាច្រើនកន្លងមក។ ជាលទ្ធផលចុងក្រោយ យើងប្រមូលថវិកាបានចំនួន **១៣៨ 000** ដុល្លារ។

យើងខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះអស់លោក លោកស្រី ដែលបានចូលរួមជាមួយយើងខ្ញុំ ក្នុងរាត្រីដ៏ចងចាំនៃការរួបរួមគ្នាដើម្បីសហគមន៍ និងការយកចិត្តទុកដាក់ចំពោះសុខភាពកុមារ។



## ជិះកង់ដើម្បីបរិស្ថាន និងសុខភាពកុមារឆ្នាំទី១១
**ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៥**

ជាលើកទី ១១ ហើយដែលព្រឹត្តិការណ៍ **«ជិះកង់ដើម្បីបរិស្ថាន និងសុខភាពកុមារ»** បានផ្តល់ឱកាសជូនបងប្អូនប្រជាពលរដ្ឋមកពីគ្រប់ទិសទីទូទាំងប្រទេស បានមកជួបជុំគ្នាបង្កើតជាទិដ្ឋភាពដ៏អស្ចារ្យដែលមានអ្នកចូលរួមរហូតដល់ទៅ ១ 000នាក់។

កាលពីឆ្នាំ ២០២៥ កន្លងទៅនេះ យើងទទួលបានថវិកាឧបត្ថម្ភយ៉ាងសំខាន់ និងផ្សព្វផ្សាយយ៉ាងទូលំទូលាយពីសហគមន៍តាមរយៈព្រឹត្តិការណ៍មួយនេះ។ ការចូលរួមយ៉ាងសកម្មរបស់កីឡាករ-កីឡាការិនី ក្រុមហ៊ុនឧបត្ថម្ភនានា ព្រមទាំងអ្នកស្ម័គ្រចិត្តក្នុងស្រុកព្រឹត្តិការណ៍នេះនៅតែបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការរស់នៅប្រកបដោយសុខភាពល្អ ព្រមទាំងបានចូលរួមចំណែកដោយផ្ទាល់ក្នុងការគាំទ្រដល់សេវាកម្មពិនិត្យ និងព្យាបាលជំងឺកុមារ ដើម្បីសង្គ្រោះជីវិតកុមារ។







## មូលនិធិសង្គ្រោះកុមារកម្ពុជាអូស្ត្រាលី

### ថ្ងៃទី២៣ ដល់ ៣០ ខែសីហា ឆ្នាំ២០២៥

យើងខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ **មូលនិធិសង្គ្រោះកុមារកម្ពុជាអូស្ត្រាលី (SCCFA)** សម្រាប់ការឧបត្ថម្ភថវិកាដ៏ថ្លៃថ្លាចំនួន **៣ ៥៦០** ដុល្លារ កាលពីឆ្នាំ២០២៥ កន្លងទៅ តាមរយៈកម្មវិធីប្រគំតន្ត្រីសប្បុរសធម៌ SCCFA Charity Concert។

ផ្តើមចេញពីការប្តេជ្ញាចិត្តខ្ពស់របស់មូលនិធិក្នុងការលើកកម្ពស់ជីវភាពរស់នៅ និងឱកាសទទួលបានការអប់រំរបស់កុមារ និងយុវជនខ្វះខាត ជំនួយដ៏មានតម្លៃរបស់ SCCFA បានក្លាយជាកម្លាំងចលករយ៉ាងសំខាន់ក្នុងការជំរុញបេសកកម្មរបស់យើងឱ្យបន្តទៅមុខ។ យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេស ចំពោះ លោកស្រី ប៊ុន ឡីវីសិដា សម្រាប់ការគាំទ្រដ៏អស្ចារ្យមួយនេះ។






## ក្តីសង្ឃឹមសម្រាប់ក្រុមគ្រួសារកុមារភៀសសឹក

### ខែវិច្ឆិកា ដល់ ធ្នូ ឆ្នាំ២០២៥

តាមរយៈកិច្ចសហការជាមួយ លោក **Charles Calvino Hang** ដែលជាបុគ្គលគំរូក្នុងសកម្មភាពមនុស្សធម៌ យុទ្ធនាការចុងឆ្នាំនេះ បាននាំយកនូវជំនួយដ៏សំខាន់ៗ និងការពិនិត្យសុខភាពដោយផ្ទាល់ជូនដល់ក្រុមគ្រួសារដែលផ្លាស់ប្តូរទីលំនៅ (ជនភៀសខ្លួន/សហគមន៍ងាយរងគ្រោះ)។

ដោយមានការរួមចំណែកពីអ្នកគាំទ្ររបស់លោកយ៉ាងសកម្ម Charles ប្រមូលថវិកាបានចំនួន **៦ ៥០០** ដុល្លារ។ អ្វីដែលរឹតតែវិសេសវិសាលជាងនេះទៅទៀតនោះ គឺការផ្សព្វផ្សាយពីសកម្មភាពមនុស្សធម៌របស់យើង ទៅកាន់មិត្តភក្តិ និងដៃគូនៅជុំវិញសកលលោក។






## យុទ្ធនាការ “រួមគ្នាប្រយុទ្ធប្រឆាំងជំងឺមហារីកកុមារ”

### ថ្ងៃទី០៦ ដល់ ៣១ ខែតុលា ឆ្នាំ២០២៥

យុទ្ធនាការអំពាវនាវប្រចាំឆ្នាំរបស់យើង បានប្រមូលផ្តុំសប្បុរសជន និងដៃគូជាច្រើនរូបរួមគ្នាក្រោមចក្ខុវិស័យតែមួយ នោះគឺ៖ **«រួមគ្នាប្រយុទ្ធប្រឆាំងជំងឺមហារីកកុមារ»**។

តាមរយៈទឹកចិត្តសប្បុរសដ៏លើសលប់ពីគ្រប់ទិសទី យើងទទួលបានថវិកាឧបត្ថម្ភសរុបចំនួន **៧៤ ៦៣១,៩៩** ដុល្លារ។

យុទ្ធនាការនេះ បានរួមចំណែកយ៉ាងសំខាន់ក្នុងការគាំទ្រដល់ផ្នែកព្យាបាលជំងឺមហារីក និងជាពិសេសគឺជួយដល់កុមារដែលកំពុងផ្ទុកជំងឺមហារីកផ្ទាល់តែម្តង។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ក្រុមហ៊ុន បុរី ប៉េង ហួត ឌីជេ ណាណា លោកសាយ ព្រមទាំងសប្បុរសជនជាច្រើនរូបទៀត ដែលបានរួមដៃគ្នាយ៉ាងសកម្មដើម្បីបង្កើតលទ្ធផលដ៏មានអត្ថន័យនេះ។








## រត់ រៃអង្គាសមូលនិធិ ជួយសង្គ្រោះជីវិតកុមារ

### ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២៥

ក្រោមស្មារតីរួមគ្នាតែមួយគឺ **«រត់ រៃអង្គាសមូលនិធិ ជួយសង្គ្រោះជីវិតកុមារ»** ក្រុមអត្តពលិកជាតិ និងអន្តរជាតិបានរួមគ្នាយ៉ាងសកម្ម ដើម្បីរត់ក្នុងបុព្វហេតុសង្គ្រោះជីវិតជូនដល់មន្ទីរពេទ្យកុមារអង្គរ នៅក្នុងព្រឹត្តិការណ៍រត់ប្រណាំងពាក់កណ្តាលម៉ារ៉ាតុងអន្តរជាតិអង្គរវត្ត។

ពេញមួយឆ្នាំ២០២៥ កន្លងទៅនេះ មន្ទីរពេទ្យកុមារ-អង្គរមានមោទនភាពយ៉ាងក្រៃលែង ក្នុងការកៀរគរមូលនិធិសប្បុរសធម៌ស្របពេលជាមួយនឹងព្រឹត្តិការណ៍រត់ប្រណាំងនេះ។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបងប្អូនគ្រប់រូបទាំងអស់ ដែលបានអញ្ជើញមកចូលរួម ផ្តល់កម្លាំងចិត្ត និងចូលរួមបរិច្ចាគ។ ជាលទ្ធផល យើងទទួលបានថវិកាឧបត្ថម្ភដ៏ច្រើនលើសលប់រហូតដល់ទៅ **៩៩ ៥១៥,៩៥** ដុល្លារ ពីសប្បុរសជននៅជុំវិញសកលលោក។









**បេសកកម្មជិះកង់ដើម្បីកុមារកម្ពុជា៖ ធ្វើដំណើរជាមួយរិទ្ធិ**

**ខែមិថុនា ឆ្នាំ២០២៤ - បច្ចុប្បន្ន**

**លោក ទីវ តារារិទ្ធិ** នៅតែបន្តដំណើរជិះកង់ជុំវិញពិភពលោកដ៏អស្ចារ្យ ដោយការជិះកង់ឆ្លងកាត់ប្រទេសជាច្រើន និងការប្តេជ្ញាចិត្តយ៉ាងមុតមាំឥតដែនកំណត់ ដើម្បីលើកកម្ពស់និងផ្សព្វផ្សាយពីសុខភាពកុមារកម្ពុជានៅលើឆាកអន្តរជាតិ។

គិតមកទល់ពេលនេះ លោកបានជិះកង់អស់រយៈពេលជាង ២៣ខែ ឆ្លងកាត់បណ្តាប្រទេសចំនួន ៣៨ ដោយគ្របដណ្តប់លើចម្ងាយផ្លូវសរុបជាង ៥៥ ០០០ គីឡូម៉ែត្រ។

តាមរយៈយុទ្ធនាការដ៏មានអត្ថន័យនេះ លោកប្រមូលថវិកាឧបត្ថម្ភយ៉ាងសំខាន់បានចំនួនជាង **២០០ ០០០** ដុល្លារដើម្បីគាំទ្រដល់កុមារនៅក្នុងប្រទេសកម្ពុជា។




សូមថ្លែងអំណរគុណ និងដឹងគុណចំពោះសប្បុរសជន អ្នករៀបចំព្រឹត្តិការណ៍នានា និងអ្នកគាំទ្រដ៏អស្ចារ្យជាច្រើនផ្សេងទៀតដែលបានលះបង់ និងជួយជ្រោមជ្រែងពួកយើងនៅក្នុងឆ្នាំនេះ។ មិនថាលោកអ្នកបានចូលរួមរត់ប្រណាំង រៀបចំយុទ្ធនាការផ្សេងៗ ឬជួយចែករំលែករឿងរ៉ាវរបស់យើងក៏ដោយ ការលះបង់របស់អ្នកទាំងអស់គ្នា បានប្រែក្លាយថវិកាទាំងនោះទៅជាការសង្គ្រោះជីវិតកុមារជាច្រើន។

សូមអរគុណសម្រាប់ការបង្កើតឱ្យមានព្រឹត្តិការណ៍ទាំងនេះ ដើម្បីផ្តល់ឱ្យកុមារនៅកម្ពុជា ទទួលបានការថែទាំប្រកបដោយគុណភាពខ្ពស់ និងប្រកបដោយក្តីមេត្តាករុណា។








ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ

សាររបស់សាស្ត្រាចារ្យវេជ្ជបណ្ឌិត ងួន ច័ន្ទភក្ត្រា

ទិន្នន័យឆ្នាំ២០២៥

សូចនាកររាស់វែងសកម្មភាពអនុវត្តការងារឆ្នាំ២០២៥

ការអភិវឌ្ឍថ្មីៗក្នុងឆ្នាំ២០២៥

ការបោះជំហានឆ្ពោះទៅមុខរបស់មន្ទីរពេទ្យកុមារអង្គរ

ការលើកកម្ពស់សម្រាប់អនាគតជំនាន់ក្រោយ

អបអរសាទរដល់អ្នកផ្តល់ប្រឹក្សាក្នុងឆ្នាំ២០២៥

ជួបជាមួយវេជ្ជបណ្ឌិតបញ្ចប់ការសិក្សារបស់យើង

ព្រឹត្តិការណ៍ធំៗរបស់មន្ទីរពេទ្យកុមារអង្គរ

**អភិបាលកិច្ច**

របាយការណ៍ហិរញ្ញវត្ថុ

សេចក្តីថ្លែងអំណរគុណ






# អភិបាលកិច្ចមន្ទីរពេទ្យកុមារអង្គរ

មន្ទីរពេទ្យកុមារអង្គរ ត្រូវបានគ្រប់គ្រង និងដឹកនាំដោយក្រុមប្រឹក្សាភិបាលស្ម័គ្រចិត្ត។ ក្រុមប្រឹក្សាភិបាល មានការទទួលខុសត្រូវក្នុងការត្រួតពិនិត្យលើការអនុវត្តយុទ្ធសាស្ត្ររបស់មន្ទីរពេទ្យ សកម្មភាពកៀរគរមូលនិធិ ការគ្រប់គ្រងហានិភ័យយុទ្ធសាស្ត្រ ការដឹកនាំ និងគណនេយ្យភាព។ សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ មិនទទួលបានកម្រៃ ឬប្រាក់ឈ្នួលណាមួយសម្រាប់ការបំពេញការងាររបស់ពួកគេឡើយ។

## ទីប្រឹក្សាភិបាល

- Kenro Izu (ស្ថាបនិក)
- Soum Sambath (ប្រធាន)
- Paul Bamatter
- Lindsay Cooper
- Lim Dararith
- Stuart Davy
- Professor Nick Day
- Robert Gazzi
- Keo Lundi
- Chea Sokleang
- Lawrence Tsang
- Va Vireak
- Professor Shunmay Yeung

## គណៈកម្មាធិការនៃក្រុមទីប្រឹក្សាភិបាល

គណៈកម្មាធិការហិរញ្ញវត្ថុ សវនកម្ម និងគ្រប់គ្រងហានិភ័យ

- Lawrence Tsang (ប្រធាន)
- Stuart Davy
- Robert Gazzi
- Soum Sambath

គណៈកម្មាធិការរៃអង្គាសមូលនិធិ

- Paul Bamatter (ប្រធាន)
- Lindsay William Cooper
- Lim Dararith
- Robert Gazzi
- Keo Lundi
- Chea Sokleang
- Va Vireak

គណៈកម្មាធិការធនធានមនុស្ស និងការតែងតាំង

- Keo Lundi (ប្រធាន)
- Soum Sambath
- Robert Gazzi

គណៈកម្មាធិការអប់រំ វេជ្ជសាស្ត្រ និងក្រមសីលធម៌

- Professor Shunmay Yeung (ប្រធាន)
- Professor Nick Day

## ទីប្រឹក្សាភិបាលប្រចាំចក្រភពអង់គ្លេស

- Denys Firth (ប្រធាន)
- Aurore Gil (បេឡាធិការ)
- Dr Michael Carter
- Catherine Gaynor
- Robert Gazzi
- Lisa Genasci

## ទីប្រឹក្សាភិបាលប្រចាំប្រទេសអាមេរិក

- Dr Robert Nassau (ប្រធាន)
- Chris Chapman (លេខា និងបេឡាធិការ)
- John Canan
- Kevin Gandhi
- Robert Gazzi
- Lisa Genasci

ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ

សាររបស់សាស្ត្រាចារ្យវេជ្ជបណ្ឌិត ងួន ច័ន្ទភក្ត្រា

ទិន្នន័យឆ្នាំ២០២៥

សូចនាករវាស់វែងសកម្មភាពអនុវត្តការងារឆ្នាំ២០២៥

ការអភិវឌ្ឍថ្មីៗក្នុងឆ្នាំ២០២៥

ការបោះជំហានឆ្ពោះទៅមុខរបស់មន្ទីរពេទ្យកុមារអង្គរ

ការលើកកម្ពស់សម្រាប់អនាគតជំនាន់ក្រោយ

អបអរសាទរដល់អ្នកផ្ដល់ប្រឹក្សាក្នុងឆ្នាំ២០២៥

ជួបជាមួយវេជ្ជបណ្ឌិតបញ្ចប់ការសិក្សារបស់យើង

ព្រឹត្តិការណ៍ធំៗរបស់មន្ទីរពេទ្យកុមារអង្គរ

អភិបាលកិច្ច

**របាយការណ៍ហិរញ្ញវត្ថុ**

សេចក្តីថ្លែងអំណរគុណ



# របាយការណ៍ហិរញ្ញវត្ថុ

## ប្រភពមូលនិធិ

មូលនិធិសរុបដែលបានពីការបរិច្ចាគឆ្នាំ២០២៥៖
**៥,៣ លានដុល្លារអាមេរិក**




- មូលនិធិអន្តរជាតិ និងស្ថាប័ននានា
- សប្បុរសជន និងព្រឹត្តិការណ៍រៃអង្គាសអន្តរជាតិ
- មូលនិធិក្នុងប្រទេស
- មូលនិធិពីរដ្ឋាភិបាលបរទេស
- ភាគទានអ្នកជំងឺ
- ចំនូលផ្សេងៗទៀត

## ការប្រើប្រាស់មូលនិធិ

មូលនិធិសរុបដែលបានប្រើប្រាស់ ឆ្នាំ២០២៥៖
**៥,៦ លានដុល្លារអាមេរិក**




- ការពិនិត្យ ថែទាំ ផ្នែកឯកទេសកុមារ
- ការពិនិត្យ ថែទាំ ផ្នែកកុមារទូទៅ
- ការពង្រឹងប្រព័ន្ធសុខភាព សហគមន៍ និងការស្រាវជ្រាវ
- ដៃគូទំនាក់ទំនង
- ចំណាយគាំទ្របេសកកម្មស្នូល
- ការបណ្តុះបណ្តាល
- កម្មវិធីគាំពារ ការព្យាបាល និងថែទាំផ្សេងៗ

** ជំនួយជាសម្ភារៈនិងបរិក្ខារ មានចំនួនតិចជាង ១% ក្នុងអំឡុងឆ្នាំ២០២៥*

នៅក្នុងឆ្នាំ២០២៥ យើងប្រមូលបានថវិកាចំនួន **៥,៣ លានដុល្លារអាមេរិក** ដើម្បីគាំទ្រដល់សេវាថែទាំសុខភាពដ៏សំខាន់សម្រាប់កុមារនៅទូទាំងប្រទេស។ ទោះបីជាចំណូលប្រតិបត្តិការរបស់យើងបានបង្ហាញពីការធ្លាក់ចុះក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះក៏ដោយ ក៏ប្រភពមូលនិធិរបស់យើងនៅតែមានភាពរឹងមាំ ដែលទទួលបានមកពីប្រភពចម្រុះជាច្រើន។ លើសពីនេះ យើងបានកៀរគរថវិកាឧបត្ថម្ភដោយជោគជ័យប្រមាណ **៣ លានដុល្លារអាមេរិក** សម្រាប់មូលនិធិ Endowment Fund ដែលជួយពង្រឹងដល់ស្ថិរភាពហិរញ្ញវត្ថុរយៈពេលវែងរបស់អង្គភាព និងធ្វើឱ្យមូលនិធិសរុបកើនឡើងដល់ **៥,១ លានដុល្លារអាមេរិក** នៅត្រឹមចុងឆ្នាំ។

ការចំណាយសរុបរបស់យើងនៅតែមានកម្រិតស្ថិរភាពក្នុងរយៈពេលបីឆ្នាំកន្លងមកនេះ ដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការរក្សាសេវាសំខាន់ៗ ទោះបីជាមានការប្រែប្រួលនៃមូលនិធិពីខាងក្រៅក៏ដោយ។ នៅក្នុងឆ្នាំ២០២៥ ជិតពីរភាគបីនៃការចំណាយទាំងអស់ត្រូវបានប្រើប្រាស់ទៅលើការថែទាំសុខភាពកុមារទូទៅ និងឯកទេស ដើម្បីធានាថាកុមារនៅតែបន្តទទួលបានការព្យាបាលវេជ្ជសាស្ត្រប្រកបដោយគុណភាពខ្ពស់ ដោយមិនគិតពីលទ្ធភាពបង់ប្រាក់របស់គ្រួសារពួកគេឡើយ។ ធនធានដែលនៅសេសសល់ត្រូវបានប្រើប្រាស់សម្រាប់ផ្តល់ហិរញ្ញប្បទានដល់កម្មវិធីសុខភាពសហគមន៍ ការអប់រំវេជ្ជសាស្ត្រ ការស្រាវជ្រាវ និងគំនិតផ្តួចផ្តើមពង្រឹងប្រព័ន្ធសុខាភិបាល។

ដោយសារតែការចំណាយក្នុងឆ្នាំ២០២៥ មានចំនួនលើសចំណូលប្រតិបត្តិការ យើងបានប្រើប្រាស់ប្រាក់បម្រុងប្រតិបត្តិការមួយផ្នែកដោយភាពវៃឆ្លាត ដើម្បីធានាឱ្យបាននូវការថែទាំប្រកបដោយនិរន្តរភាព និងឆ្លើយតបទៅនឹងតម្រូវការថែទាំសុខភាពដែលកំពុងតែកើនឡើង។

ទន្ទឹមនឹងការទន្ទឹងរង់ចាំមើលទៅថ្ងៃអនាគត យើងនៅតែបន្តផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការធ្វើពិពិធកម្មប្រភពមូលនិធិរបស់យើង និងការពង្រឹងភាពជាដៃគូយុទ្ធសាស្ត្រឱ្យកាន់តែស៊ីជម្រៅ ដើម្បីធានាបាននូវនិរន្តរភាពរយៈពេលវែងនៃសេវាកម្មរបស់យើង ធ្វើយ៉ាងណាឱ្យកុមារកាន់តែច្រើននៅទូទាំងប្រទេសកម្ពុជាអាចទទួលបានសេវាថែទាំសុខភាពដែលពួកគេត្រូវការ។

ចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃ

សាររបស់សាស្ត្រាចារ្យវេជ្ជបណ្ឌិត ងួន ច័ន្ទភក្ត្រា

ទិន្នន័យឆ្នាំ២០២៥

សូចនាកររាស់វែងសកម្មភាពអនុវត្តការងារឆ្នាំ២០២៥

ការអភិវឌ្ឍថ្មីៗក្នុងឆ្នាំ២០២៥

ការបោះជំហានឆ្ពោះទៅមុខរបស់មន្ទីរពេទ្យកុមារអង្គរ

ការលើកកម្ពស់សម្រាប់អនាគតជំនាន់ក្រោយ

អបអរសាទរដល់អ្នកផ្តល់ប្រឹក្សាក្នុងឆ្នាំ២០២៥

ជួបជាមួយវេជ្ជបណ្ឌិតបញ្ចប់ការសិក្សារបស់យើង

ព្រឹត្តិការណ៍ធំៗរបស់មន្ទីរពេទ្យកុមារអង្គរ

អភិបាលកិច្ច

របាយការណ៍ហិរញ្ញវត្ថុ


**សេចក្តីថ្លែងអំណរគុណ**





# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះការគាំទ្រជាច្រើនឆ្នាំកន្លងមករបស់លោកអ្នក ដើម្បីជួយសង្គ្រោះជីវិតកុមាររាប់លាននាក់នៅទូទាំងប្រទេសកម្ពុជា។

សូមថ្លែងអំណរគុណយ៉ាងអនេកចេញពីជម្រៅនៃចិត្តរបស់យើងទាំងអស់គ្នានៅមន្ទីរពេទ្យកុមារអង្គរ។

ពេញមួយឆ្នាំ ២០២៥ កន្លងទៅនេះសប្បុរសជនជាតិ និងអន្តរជាតិរបស់យើងបានបង្ហាញនូវការប្តេជ្ញាចិត្ត ក្តីមេត្តាករុណា និងការចូលរួមចំណែកដ៏មានសារៈសំខាន់ចំពោះបេសកកម្មរបស់យើង។

យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាពិសេសចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលបានផ្តល់ការគាំទ្រយ៉ាងច្រើនដល់ពួកយើងក្នុងរយៈពេល ២៦ឆ្នាំ ចុងក្រោយនេះ៖

- ក្រសួងសុខាភិបាល
- ឃ្លាំងឱសថកណ្តាល (កម្ពុជា)
- មជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងជំងឺអេដស៍ ជំងឺសើស្បែក និងជំងឺកាមរោគ
- មន្ទីរសុខាភិបាលខេត្តសៀមរាប
- មន្ទីរសុខាភិបាលខេត្តព្រះវិហារ
- ក្រសួងទេសចរណ៍
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនៃព្រះរាជាណាចក្រកម្ពុជា
- ក្រសួងការបរទេស និងសហប្រតិបត្តការអន្តរជាតិ
- គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា
- អាជ្ញាធរជាតិអប្សរា

## ការគាំទ្រតាមរយៈស្ថាប័នបណ្តុះបណ្តាល

- American Society of Hematology
- Boston Children’s Hospital
- Children’s Healthcare of Atlanta
- Children’s Wisconsin
- FH Joanneum
- Guarantors of Brain
- Health Volunteers Overseas
- St. Jude's Children Research Hospital
- Tulane University School of Medicine
- University of Oxford
- University of Pittsburgh School of Nursing
- UMass Chan Medical School

## មូលនិធិមរតក “ក្លូឌៀ ធីណឺ” Endowment Fund

- ABA Bank
- Bill and Renee Selman
- Michael Keown
- Michael Todorovich

## មូលនិធិ និងបរធនបាលកិច្ច

- Carraresi Foundation, in memory of AUGUSTO CARRARESI
- Diana Koh Fund
- Dr. Ernst-Günther Bröder Foundation
- GHR Foundation
- Herbalife Family Foundation
- Hikarikanata Foundation
- Kadoorie Charitable Foundation
- Kids International Development Society
- Leon Judah Blackmore Foundation
- Ping & Amy Chao Family Foundation
- Ptarmigan Charitable Foundation
- Y.P. Charitable Foundation
- Seva Foundation
- The Lloyd George Foundation
- The Transparent Fish Fund
- The Canada Fund for Local Initiatives (CFLI)
- Vitol Foundation

## ព្រឹត្តិការណ៍រៃអង្គាស និងសប្បុរសជនរៀបចំព្រឹត្តិការណ៍រៃអង្គាស

- គ្រឹះស្ថានអង្គរ (Angkor Enterprise)
- អ្នកម្តាយមនុស្សធម៌ (Neak Mday Monusothor)
- 777 Polyclinic Siem Reap
- Advanced Bank of Asia Limited
- AVIS Cambodia
- Bon Phka Prak Wat Bo 2025
- CIMB Bank (Cambodia) Plc
- Cheang Bak Van Hong (CBVH)
- Chea Leangheng Dental Clinic
- Charles Calvino Hang
- Cycling for Environment and Children's Health
- Friends Without A Border (FWAB)
- Khmer Korea Sermon Association
- Kofi Co., Ltd
- Khinery BE Co., Ltd
- KK Running Club
- Ly Hour Group
- Mrs Demaz Tep Baker
- Nick and Ali Bamatter
- Neak Tep Hospital
- Nerou Cheng
- One Fraternity Co. Ltd
- Royal Angkor International Hospital
- SentBe
- Southbridge International School Cambodia (SISC)
- Tiv Dararith
- TP MORAL CONSTRUCTION AND DEVELOPMENT CO., LTD
- The Heritage Walk
- Tourist Transport Association For Siem Reap International Airport
- Toby and Pippa Gresham
- VIPASSA
- WING Bank (Cambodia) Plc
- Walk Bokor for Children's Health

## សប្បុរសជន និងក្រុមគ្រួសារសប្បុរសជន

- Samdech Preah Mahaksatrey Norodom Monineath Sihanouk
- Ailsa Lo
- Ben and Jo Hendry-Prior
- Chae Sokheng
- Claudio V. Albertin; Switzerland
- Dongni An
- Dr Allen C. Johnson and his wife, Janet
- Dr Marvin Godner
- Dr Michael Wall
- Dr Kamachi and his group with support from Friends Without A Border Japan
- Gregor McKellar
- Jean-Paul and Tamsin Churchouse
- Jeff and Samantha Roskell
- John and Marion Canan
- Jonathan Hudson
- Katherine and Peter Meiklejohn
- Lo Bunleng and Lap Chaikim
- Marc and Erin Locatelli
- Mr Van Hong and Mrs Imphan Vanndy
- Neak Oknha Hun Lak
- Richard Henker
- Richard Mark Appleby
- Rithy Thach via the Valley United Way
- Rob and Ticker Rankin in memory of Nathaniel (Nat) Kirby Rankin
- Steve and Suzanne Brown
- Sue and Stuart Davy
- SRENG VOUCH IM
- Soun Sarin and Soun Koy Kim Say
- Tim and Helen Gibson
- The Leila and Bryan Giving Fund
- Tom Summersall

## ក្រុមហ៊ុន និងសាជីវកម្ម

- Borey Peng Huoth Co., Ltd
- Cambodia Red Cross
- Cambodian Red Cross Siem Reap Branch
- Cambodia Chemical Supply Co., Ltd
- Chip Mong Group
- Chea Leangheng Dental Clinic
- Dai-Ichi Life Insurance (Cambodia) Plc
- DIG FC 88
- Fame Cafe
